# ក្រុមជួយខ្លួនឯង[១]

## ក្រុមជួយខ្លួនឯងគឺ...

"...ជាវិធីមួយដើម្បីចាប់យកការងារណាដែលជួយកសាងដល់ទំនាក់ទំនងសង្គមធ្វើឱ្យមនុស្ស ទទួលបាននូវផលប្រយោជន៍សម្រាប់ទ្រទ្រង់ដល់គោលដៅចិញ្ចឹមជីវិតរបស់ពួកគាត់ "

"...ជួយដល់ប្រជាជនឱ្យនិយាយឯកភាពគ្នា ដោយធ្វើឱ្យមានសម្លេងកាន់តែខ្លាំងឡើង លើការសម្រេចចិត្ត និងការចរចាប្រកបដោយឋាមវន្តច្រើនថែមទៀត "

"**ក្រុមជួយខ្លួនឯង** ចិញ្ចឹមត្រីនៅតាមជនបទ (West Bengal) ទទួលបានជោគជ័យយ៉ាងធំធេង។ ពួកគាត់សន្សំប្រាក់បានយ៉ាងច្រើនបំផុត និងទទួលបានប្រាក់កម្ចីមួយចំនួនធំទៀតផង។"
- *Ajit Banerjee,* នាយកសាខាធនាគារ, *Ludhurka, Purulia, West Bengal,* ប្រទេសឥណ្ឌា

"ភូមិរបស់ខ្ញុំមានចម្ងាយ ៣០ គ.មពីទីប្រជុំជន។ កាលពីមុន ពុំមានទីណាមួយអាចសុំនូវការជួយបានឡើយ ប៉ុន្តែក្រោយពេលដែលមាន*ក្រុមជួយដោយខ្លួនឯង* មក ធ្វើឱ្យប្រជាជន មានការកក់ក្តៅ និងមានទំនុកចិត្តក្នុងការសុំរកការគាំទ្រដល់ពួកគាត់។" - *Kuddus Ansary, Jankar (Self-Help Group leader), Kaipara, West Bengal, India*

"...ជាវិធីមួយសម្រាប់បង្កើនប្រសិទ្ធភាពសកម្មភាពនានាតាមមូលដ្ឋាន"

"...ផ្តល់ឱ្យទទួលបានយ៉ាងងាយនូវប្រភពឥណទានតូចតាច និងធនធាន ក៏ដូចជាការងារផ្សេងៗទៀត "

ក្រុមជួយដោយខ្លួនឯង គឺជាវិធីពិតប្រាកដមួយសម្រាប់កសាងធនធានសង្គម។ សកម្មភាពដ៏ទៃទៀតរួមមាន :



**ការកសាងបណ្តាញការងារ និងការទំនាក់ទំនងគ្នា** ដើម្បីបង្កើនសមត្ថភាពរបស់អ្នកផ្តល់ និងអ្នកបម្រើសេវាឱ្យបំពេញការងាររួមគ្នា ឬដើម្បីពង្រឹងខ្សែបណ្តាញទំនាក់ទំនងរវាងបុគ្គលជាមួយនឹងការរួមគ្នាទទួលប្រយោជន៍ និងពង្រីកឱកាសដល់ពួកគាត់ឱ្យក្លាយជាផ្នែកមួយនៃស្ថាប័ន ដូចជា អង្គការនយោបាយ ឬអង្គការមហាជន។



**គាំទ្រដល់សមាជិកភាពក្រុមទាំងឡាយដែលបានរៀបចំទម្រង់បែបបទបានគ្រប់គ្រាន់** ហើយតែងតែពាក់ព័ន្ធដល់ជនទាំងឡាយណាដែលយល់ព្រម និងទទួលយកនូវច្បាប់ និងរបៀបរបបទាំងអស់នោះ និងឯកភាពផងដែរចំពោះវិន័យដែលត្រូវប្រកាន់យក ក្នុងករណីបើមានជនណាមួយមិនគោរពតាមច្បាប់ទាំងនោះ។



សម្ភារៈ និងការតភ្ជាប់ជាមួយនឹងទីផ្សារ។

**កសាងទំនាក់ទំនងជំនឿទុកចិត្ត** (ដែលហៅថា "**ផ្តល់ឱ្យ និងទទួលយក**") ផ្លាស់ប្តូរព័ត៌មាន ធ្វើការងាររួមគ្នា សហប្រតិបត្តិការ និងកាត់បន្ថយនូវការលំបាកពាក់ព័ន្ធនឹងការធ្វើអ្វីមួយដែលអាចផ្តល់ឱ្យនូវមូលដ្ឋានសម្រាប់បណ្តាញសុវត្ថិភាពព័ត៌មានក្នុងចំណោមមហាជន (ជួយគ្នាទៅវិញទៅមក)។ នេះអាចជាការជួយគ្នាទៅវិញទៅមករវាងក្រុមមួយ និងក្រុមមួយទៀត និងអាចមានទម្រង់ជាសហព័ន្ធនៃក្រុមជួយខ្លួនឯង។

សហព័ន្ធនៃក្រុមជួយខ្លួនឯង គឺមានភាពល្អសម្រាប់កសាងទំនាក់ទំនងជាមួយអ្នកផ្តល់សេវា រួមមាន ការផ្សព្វផ្សាយ និងសេវាកម្មរបស់អង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល វិស័យធនាគារជនបទ អ្នកផ្គត់ផ្គង់

"រួមគ្នារវាងក្រុមជួយខ្លួនឯង ការស្រាវជ្រាវវារីវប្បកម្ម និងឥណទានជនបទដែលបានពង្រឹងដល់សន្តិសុខស្បៀង និងមានការប្រាក់ទាបសម្រាប់អ្នកភូមិចាបារ៉ា នៅប្រទេសឥណ្ឌា" - ប្រព័ន្ធតាមជនបទ របាយការណ៍ប្រចាំឆ្នាំ ២០០៣-២០០៤

*ឡាលីតា ម៉ាហាតូ ជាស្ត្រីបង់ហ្កាលីចំណាស់ម្នាក់* "គ្មានពេលណាមួយដែលធ្វើឱ្យយើងមិនហ៊ាននិយាយទៅកាន់បុរសនៅក្នុងភូមិដោយគិតថាជារឿងចំឡែកនោះឡើយ។ សព្វថ្ងៃនេះ យើងអាចទៅធនាគារដើម្បីសុំខ្ចីប្រាក់ ចូលជួបអជ្ញាធរប៉េនចាយ៉ាត និងរាយការណ៍ពីការឈឺចាប់របស់ពួកយើង និងការប្រឈមមុខជាមួយនឹងការប្រណាំងប្រជែង។ ពួកយើងសប្បាយចិត្តណាស់ដែលត្រូវបានគេគោរព និ ងស្តាប់នូវសម្លេងរបស់យើង។





# របៀបបង្កើតក្រុមជួយខ្លួនឯង

## ការចាប់ផ្ដើម

### ១_ មើលថាតើក្រុមបង្កើតហើយឬនៅ

ប្រសិនបើក្រុមបង្កើតរួចហើយ តើយើងអាចចុះពិនិត្យវាបានទេ។ ប្រសិនបើយើងមាននូវអ្វីដែលយើងស្វែងរកហើយនោះ យើងមិនចាំបាច់បង្កើតក្រុមជួយខ្លួនឯងឡើយ។ ប្រសិនបើមិនទាន់មានទេយើងអាចរៀនសូត្រពីអ្វីដែលយើងបានឃើញនៅទីនោះ។

### ២_ ធ្វើការជាមួយអ្នកដទៃ និងស្វែងរកការជួយជ្រោមជ្រែង

ចាប់ផ្ដើមជាក្រុម ដែលសមាជិកគ្រប់គ្នាមានភាពម្ចាស់ការ។ ព្យាយាមទំនាក់ទំនងជាមួយនរណាម្នាក់ដែលបានជួបជាមួយក្រុមរួចហើយ។ ប្រសិនបើមានសមាជិកថ្មីចូលរួម ត្រូវជួយពួកគេឱ្យរៀបចំក្រុមនោះឡើង ពីព្រោះ វាមានសារសំខាន់ណាស់សម្រាប់ឱ្យសមាជិនីមួយៗអាចចូលរួមចំណែកបាន។ គិតគូរឱ្យមានការជួយបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈដល់អ្នកដែលចាប់អារម្មណ៍ដល់សេចក្ដីត្រូវការរបស់យើង និងមានសុឆន្ទៈជួយដល់ការខំប្រឹងប្រែងរបស់យើង។ គ្រប់គម្រោង ធនាគារ អង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្សព្វផ្សាយអាចទទួល បានប្រយោជន៍ផ្សេងៗគ្នាពីការផ្ដល់នូវទីកន្លែងប្រជុំដល់ប្រភពដែលត្រូវការនូវទីតាំងនោះ។

### ៣_ ចាប់ផ្ដើមពីតូចទៅ

ចាប់ផ្ដើមដោះស្រាយបញ្ហាចាប់ពីតិចតួចទៅ ពេលនោះអាចនៅមានសេសសល់បញ្ហាខ្លះៗ ហើយជាទូទៅ ត្រូវតែធ្វើវាឱ្យបានសម្រេចខ្លួនឯងសិន មុននឹងផ្ដល់ឱ្យមហាជន។ ក្រុមតូចៗគឺមិនសូវមានមតិខ្វែងគ្នាច្រើនឡើយ ឬក៏មានការគាបសង្កត់ពីក្រុមភាគតិចណាឡើយ។ ក្រុមដែលមានសាវតាប្រហាក់ប្រហែលគ្នា និងមានផលប្រយោជន៍រួមគ្នា គឺប្រហែលជាអាចមានការជឿទុកចិត្ត គ្នាទៅវិញទៅមក ហើយព្រមចូលហ៊ុនរួមគ្នាសម្រាប់ធ្វើសកម្មភាពនានាទៀតផង។

### ៤_ ជ្រើសរើសឈ្មោះដាក់ឱ្យក្រុម

ឈ្មោះរបស់ក្រុមជួយឱ្យសមាជិកមានអារម្មណ៍ថាជាផ្នែកមួយនៃពួក (Team) ដែលអាចបំពេញការងារឈានឆ្ពោះទៅរកគោលដៅរួម។ វាជួយ ឱ្យសមាជិកទាំងអស់ប្រមូលផ្ដុំឋាមពលរួមគ្នា។

### ៥_ យល់ព្រមលើការតែងតាំង

ការតែងតាំងរបស់អ្នកគឺជាការសរសេរកត់ត្រានូវគោលបំណង និងវិន័យសម្រាប់ក្រុម អ្វីដែលរំពឹងទុកសម្រាប់ក្រុម និងអ្វីដែលសមាជិកក្រុមសង្ឃឹមថានឹងទទួលបានពីក្រុមមកវិញ។ ទាំងនេះក៏អាចបញ្ចៀសបាននូវទំនាស់ និងធ្វើឱ្យរឹតតែច្បាស់លាស់នូវការទទួលខុសត្រូវរបស់សមាជិកនីមួយៗ។

### ៦_ យល់ព្រមលើទីកន្លែង និងពេលវេលាប្រជុំ

លើកទឹកចិត្តដល់ការចូលរួមរបស់បុរស និងស្ត្រី (ដាច់ពីគ្នា ឬរួមគ្នា)។ ខិតខំផ្ដល់នូវទីកន្លែងល្អសម្រាប់ការចូលរួមរបស់បុរស និងស្ត្រី និងលើកទឹកចិត្តឱ្យពួកគាត់មានជំនាញដឹកនាំគ្រប់ៗគ្នា។ ប្រសិនបើអ្នកប្រមើលមើលដល់ក្រុមតូចៗ និងមានអារម្មណ៍ពេញចិត្តនឹងគំនិតណានោះ គិតថាការប្រជុំបានផ្ដួចផ្ដើមឡើងនៅឯផ្ទះរបស់សមាជិកណាម្នាក់។ ទន្ទឹមនឹងនេះផងដែរ ព្យាយាមកំណត់នូវពេលវេលាសមស្របណាមួយសម្រាប់ឱ្យសមាជិកទាំងអស់ចងចាំនូវការប្រជុំ ឧទាហរណ៍ ថ្ងៃអង្គារ៍ ទី ១ នៃខែ។







**ចំណុចសំខាន់ៗមួយចំនួន...**





**ការលើកទឹកចិត្ត :**

- ការចូលរួមប្រជុំក្រុមជាប្រចាំ
- តម្លាភាពគឺជារបៀបនៃការបំពេញការងារ ការកត់ត្រា (ដូចជាសៀវភៅកំណត់ហេតុ បញ្ជីវត្តមាន បញ្ជីចំណាយ) ជួយក្រុមការងារឱ្យចាំបាននូវអ្វីដែលបានសម្រេចចិត្តនៅក្នុងអង្គប្រជុំ។ របាយការណ៍ទាំងអស់នោះ សំខាន់ណាស់សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ។

**ឧទាហរណ៍ កំណត់ហេតុប្រជុំក្រុម**

| កាលបរិច្ឆេទ | របៀបវារៈ | ការពិភាក្សា | សេចក្ដីសម្រេច |
|---|---|---|---|
| ៤/៦ | សិក្ខាសាលា | បាទ | សមាជិក ៣ នាក់ចូលរួម |
| | ទិញសម្ភារ | បាទ | ២ នាក់នឹងទិញកាតាប ៣ ៦/៦ |
| | ការត្រឡប់មកវិញរបស់សាមាជិកគណៈកម្មាធិការប្រកបដោយសុវត្ថិភាព | បាទ | អត់មាន |
| ១១/៦ | របាយការណ៍សិក្ខាសាលា | បាទ | កែសម្រួលសមាសភាព |
| | របាយការណ៍លក់មាន់ | បាទ | សមាជិកទាំងអស់ផ្សព្វផ្សាយនៅឯសាលារៀន |

- ការសន្សំប្រាក់ខ្លះៗសម្រាប់បង្កើនមូលនិធិសមូហភាពឱ្យបានច្រើន សមាជិកទាំងអស់អាចអនុញ្ញាតឱ្យខ្ចីប្រាក់ពីការសន្សំរបស់ពួកគាត់នោះ និងត្រូវបង្កើនសមត្ថភាពជំនាញដល់ក្រុមទាំងមូល ជារបៀបកំណត់កំរិតការប្រាក់ ពេលវេលាត្រូវសងប្រាក់វិញ និងគ្រប់គ្រងកម្ចីឱ្យបាន ត្រឹមត្រូវដោយត្រូវអនុវត្តរបៀបទទួលឥណទានតាមរយៈធនាគារ។
- បើកកុងធនាគារសន្សំប្រាក់នៅធនាគារជនបទ ធនាគារពាណិជ្ជកម្ម ឬធនាគារសមូហករណ៍ណាមួយដែលនៅជិតបំផុត តាមរយៈការបង្កើតទំនាក់ទំនងរវាងធនាគារ និងក្រុមជួយដោយខ្លួនឯង។
- ធ្វើគ្រប់សកម្មភាពដើម្បីរកប្រាក់ចំណូលដែលអាចបង្កើតចេញជាព្រទ្យធនសម្រាប់ជួយកសាងទំនុកចិត្តផ្ទាល់ខ្លួន។
- ព្រមព្រៀងគ្នាលើការផ្លាស់ប្តូរថ្នាក់ដឹកនាំ ដែលបញ្ហាផ្លាស់ប្តូរនេះជារឿយៗគឺធ្វើឱ្យក្រុមតែងតែមិនអាចដោះស្រាយបាន និងធ្វើឱ្យមានការលំបាកដល់ការធ្វើផែនការរយៈពេលវែង។ ម្យ៉ាងវិញទៀត ការផ្លាស់ប្តូរអ្នកដឹកនាំនៅក្នុងក្រុមតែងផ្តល់ឱ្យសមាជិកទាំងអស់មានឱកាសកសាងសមត្ថភាពជំនាញលើផ្នែកដឹកនាំ និងគ្រប់គ្រងស្ថាប័ន។

បញ្ហាដែលត្រូវជៀសវាង :

- ការរើសអើងក្នុងចំណោមសមាជិកដែលមានវណ្ណៈតូចតាច សាសនា ឬការជាប់ពាក់ព័ន្ធនឹងនិន្នាការនយោបាយណាមួយ។




## អាស័យដ្ឋានទំនាក់ទំនងសំខាន់ៗ

## គោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរផ្សេងៗទៀត

មានគោលការណ៏ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរផ្សេង១ទៀត រួមមាន :

- ការក៏សាងមតិឯកភាពគ្នាជារួម
- ក្រុមជួយដោយខ្លួនឯង

លោកអ្នកអាចទទួលបានឯកសារទាំងអស់នេះ និងឯកសារគោលការណ៏ណែនាំអនុវត្តឱ្យកាន់តែប្រសើរផ្សេងទៀតពីការិយាល័យ STREAM នៅតាមប្រទេសរបស់អស់លោកអ្នក ពីការិយាល័យ STREAM ប្រចាំតំបន់ ឬពីគេហទំព័ររបស់ STREAM ។

យើងខ្ញុំសូមទទួលយកនូវរាល់ការរិះគន់ស្ថាបនាពីអស់លោកអ្នក នូវរាល់គោលការណ៏ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរ ។

អស់លោកអ្នកអាចផ្តល់នូវការរិះគន់ទាំងនោះតាមរយៈទូរស័ព្ទ អ៊ីមែល ឬសរសេរមកកាន់នាយកទំនាក់ទំនង ដែលប្រចាំការនៅតាមការិយាល័យ STREAM ប្រចាំការតាមប្រទេសរបស់អស់លោកអ្នក ។

**ការិយាល័យ STREAM ប្រចាំប្រទេសកម្ពុជាមានអាស័យដ្ឋានដូចខាងក្រោម :**

ការិយាល័យអភិវឌ្ឍន៏សហគមន៏នេសាទ ( នាយកដ្ឋានជលផល)

អាគារលេខ ១៨៦ វិថី ព្រះនរោត្តម ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : (៨៥៥ ២៣) ២១០ ១៥៤

ទូរសាលេខ : (៨៥៥ ២៣) ២១០ ១៥៤

អ៊ីមែល : **cfdo@online>com>kh**

**ការិយាល័យ STREAM ប្រចាំតំបន់ :**

អាគារ ណាកា (NACA) នាយកដ្ឋានជលផល

បរិវេណ សាកលវិទ្យាល័យកាសេតសាទ

ផ្លូវ ផ ាហូលយ៉ូស៊ីន សង្កាត់ បែងឃេន

ទីក្រុងបាងកក ១០៩០៣ ប្រទេសថៃឡង់

ទូរសព្ទលេខ : ៦៦២ ៥៦១ ១៧២៨/២៩

ទូរសាលេខ : ៦៦២ ៥៦១ ១៧២៧

អ៊ីមែល : **stream@enaca.org**

**STREAM** គេហទំព័រ : www.streaminitiative.org